**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតាមដាននិងវាយតម្លៃប្រព័ន្ធថវិកាសមិទ្ធកម្មថ្នាក់ជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីក្របខ័ណ្ឌ វិធីសាស្ត្រ យន្តការ និងនីតិវិធីនៃការតាមដាននិងវាយតម្លៃ ក្នុងក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្មថ្នាក់ជាតិ ដើម្បីរួមចំណែកជានាស័ក្តិសិទ្ធភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធកម្មកម្មវិធីរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ក្របខ័ណ្ឌទូទៅនៃការតាមដាននិងវាយតម្លៃប្រព័ន្ធថវិកាសមិទ្ធកម្ម

**មាត្រា៤ .-**

ការតាមដាននិងវាយតម្លៃគឺជាឧបករណ៍វាស់វែងសមិទ្ធកម្មជាប្រព័ន្ធ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធី ដើម្បីសម្រេចបាននូវគោលបំណងនៃកម្មវិធី។ ដំណើរការនៃការតាមដាននិងវាយតម្លៃផ្តោតទៅលើការផ្សារភ្ជាប់រវាងធាតុចូលនិងលទ្ធផលក្នុងឆ្នាំ ព្រមទាំងរវាងលទ្ធផលក្នុងឆ្នាំនិងលទ្ធផលចុងក្រោយ ដែលឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

ការតាមដាននិងវាយតម្លៃ ផ្តល់ជាឧបករណ៍ដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់-ប្រហែល ក្នុងការវាស់វែងសមិទ្ធកម្ម និងស្វែងយល់ពីកត្តាជំរុញនៃលទ្ធផលដែលសម្រេចបាន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀបចំថវិកា ការវិភាជថវិកា ព្រមទាំងឆ្លុះបញ្ចាំងពីបន្ទាត់គណនេយ្យភាពចំពោះសមិទ្ធកម្ម។

**មាត្រា៥ .-**

ការតាមដាននិងវាយតម្លៃ ត្រូវប្រើប្រាស់ក្របខ័ណ្ឌតក្កភាពនៃខ្សែចង្វាក់លទ្ធផល ដែលកំណត់នូវទំនាក់ទំនងហេតុនិងផល នៃការផ្សារភ្ជាប់រវាងសមាសភាពសំខាន់ៗរួមមានធាតុចូល និងសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក ដែលឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

**មាត្រា៦ .-**

ការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ ត្រូវអនុវត្តតាម ៦ (ប្រាំមួយ) ជំហាន ដូចខាងក្រោម៖

១- ការកំណត់ការធ្វើអន្តរាគមន៍

២- ការកំណត់សូចនាករ

៣- ការកំណត់បន្ទាត់មូលដ្ឋាន និងគោលដៅសូចនាករ

៤- ការរៀបចំវិធីសាស្ត្រប្រមូលទិន្នន័យ

៥- ការតាមដាន

៦- ការប្រើប្រាស់ទិន្នន័យពីការតាមដាន និងពីប្រភពផ្សេងទៀត សម្រាប់អនុវត្តការវាយតម្លៃ។

**មាត្រា៧ .-**

តួអង្គចូលរួមអនុវត្តការតាមដាននិងវាយតម្លៃ រួមមាន៖

- រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល
- ប្រធានកម្មវិធី
- ប្រធានអង្គភាពថវិកា
- អ្នកទទួលផលពីការអនុវត្តកម្មវិធី
- ក្រុមការងារទទួលបន្ទុកការតាមដាននិងវាយតម្លៃសមិទ្ធកម្មនៃកម្មវិធី និង
- តួអង្គពាក់ព័ន្ធចាំបាច់ផ្សេងទៀត។

## ជំពូកទី៣
## ការតាមដានសមិទ្ធកម្ម

**មាត្រា៨ .-**

ការតាមដាន សំដៅដល់ដំណើរការជាប្រព័ន្ធសម្រាប់អង្កេត និងកត់ត្រាសកម្មភាពនៃកម្មវិធីជាប្រចាំ ដើម្បីធានាឱ្យសកម្មភាពទាំងនោះត្រូវបានអនុវត្តស្របតាមគោលដៅ និងលទ្ធផលដែលបានគ្រោងទុក។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មានភារកិច្ចអនុវត្តការតាមដានសមិទ្ធកម្ម របស់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់ខ្លួនជាប្រចាំ ដោយផ្អែកលើផែនការសមិទ្ធកម្ម ដើម្បីធានា គណនេយ្យភាពសមិទ្ធកម្ម។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចពិនិត្យលើលទ្ធផលនៃការតាមដានសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីបញ្ជាក់អនុលោមភាព និងផ្តល់អនុសាសន៍កែលម្អ លើការរៀបចំថវិកា កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនៅឆ្នាំបន្ទាប់ និងជាមូលដ្ឋានសម្រាប់ធ្វើការ វាយតម្លៃកម្មវិធី អនុកម្មវិធី ឬមុខចំណាយជាក់លាក់ តាមការចាំបាច់ និងតាមការជ្រើសរើស។

**មាត្រា៩ .-**

ការតាមដានសមិទ្ធកម្ម ត្រូវអនុវត្តតាមយន្តការសំខាន់ៗចំនួន ៣ (បី) រួមមាន៖

១- ការរៀបចំផែនការសមិទ្ធកម្ម

២- របបប្រជុំតាមដានសមិទ្ធកម្ម និង

៣- ការរៀបចំរបាយការណ៍សមិទ្ធកម្ម។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវរៀបចំផែនការសមិទ្ធកម្ម ដែលជាមូលដ្ឋាន សម្រាប់ធ្វើការតាមដានជាប្រចាំនូវវឌ្ឍនភាពការងារនិងសមិទ្ធកម្មនិងធ្វើការរាយការណ៍អំពីសមិទ្ធកម្ម។

ទម្រង់នៃផែនការសមិទ្ធកម្ម និងរបាយការណ៍សមិទ្ធកម្ម ព្រមទាំងរបបប្រជុំតាមដានសមិទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០.-**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវរៀបចំផែនការសមិទ្ធកម្មប្រចាំឆ្នាំ ដើម្បីភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការកិច្ចប្រជុំពិភាក្សាគម្រោងផែនការថវិកា ដោយអនុលោមតាមសារាចររបស់រាជរដ្ឋាភិបាល ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យអនុលោមភាព និងចងក្រងផែនការសមិទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីដាក់ជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋសភានិងព្រឹទ្ធសភា។

**មាត្រា១១.-**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវរៀបចំកិច្ចប្រជុំតាមដានសមិទ្ធកម្ម កម្រិតចង្កោមសកម្មភាព កម្រិតអនុកម្មវិធី កម្រិតកម្មវិធី និងកម្រិតក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីតាមដានវឌ្ឍនភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុនិងសមិទ្ធកម្ម ក៏ដូចជាកំណត់បញ្ហាប្រឈម និងដាក់ចេញនូវយន្តការសម្របសម្រួលនិងដោះស្រាយ។

**មាត្រា១២.-**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យអនុលោមភាព និងចងក្រងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីដាក់ជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសេចក្ដីព្រាងច្បាប់ទូទាត់ថវិកា ជូនរដ្ឋសភានិងព្រឹទ្ធសភា។

**មាត្រា១៣.-**

វិធាននិងនីតិវិធីលម្អិតនៃការតាមដានសមិទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការវាយតម្លៃសមិទ្ធកម្ម
### ផ្នែកទី១
### យន្តការវាយតម្លៃ

**មាត្រា១៤.-**

ការវាយតម្លៃ សំដៅដល់វិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធក្នុងការប្រមូលទិន្នន័យ ការវិភាគ និងការប្រើប្រាស់លទ្ធផលនៃការវិភាគ ដើម្បីកំណត់អំពីភាពស្របតាមទិសដៅ និងការសម្រេចបាននូវ



ឲ

គោលបំណង ព្រមទាំងជានាបាននូវស័ក្តិសិទ្ធភាព ប្រសិទ្ធភាព កម្មវិបាក និងចីរភាពនៃកម្មវិធីដែលត្រូវបានជ្រើសរើសសម្រាប់ការវាយតម្លៃ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកផ្តួចផ្តើមនិងសម្រេចជ្រើសរើសការវាយតម្លៃសមិទ្ធកម្ម កម្រិតកម្មវិធី ឬអនុកម្មវិធី ឬមុខចំណាយជាក់លាក់ របស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងតាមការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល ក្នុងការជ្រើសរើសការវាយតម្លៃសមិទ្ធកម្មនេះ។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវចូលរួមសហការក្នុងដំណើរការវាយតម្លៃសមិទ្ធកម្ម។

**មាត្រា១៥ .-**

លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ រួមមាន ៦ (ប្រាំមួយ) ប្រភេទ ដូចខាងក្រោម៖

១- ភាពស្របតាមទិសដៅ

២- ភាពស៊ីសង្វាក់

៣- ស័ក្តិសិទ្ធភាព

៤- ប្រសិទ្ធភាព

៥- កម្មវិបាក

៦- ចីរភាព។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចជ្រើសរើសលក្ខណៈវិនិច្ឆ័យមួយចំនួន ឬទាំង ៦ (ប្រាំមួយ) ប្រភេទ ទៅតាមសារៈសំខាន់នៃគោលបំណងនៃការវាយតម្លៃ។

**មាត្រា១៦ .-**

វិធីសាស្ត្រវាយតម្លៃ រួមមាន វិធីសាស្ត្របែបបរិមាណ វិធីសាស្ត្របែបគុណភាព និងវិធីសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

ការជ្រើសរើសវិធីសាស្ត្រវាយតម្លៃ អាចមានភាពបត់បែនតាមតម្រូវការជាក់ស្តែងនៃការប្រមូលទិន្នន័យសម្រាប់វិភាគ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃដែលបានជ្រើសរើស។

**មាត្រា១៧ .-**

ការអនុវត្តការវាយតម្លៃ ត្រូវផ្អែកលើផែនការសកម្មភាពសម្រាប់ការវាយតម្លៃ ក្នុងការប្រមូល ការវិភាគ និងការបកស្រាយទិន្នន័យសម្រាប់រៀបចំលទ្ធផលនៃការវាយតម្លៃ។ លទ្ធផលនៃការវាយតម្លៃ និងការផ្តល់អនុសាសន៍ ត្រូវបង្ហាញក្នុងរបាយការណ៍លទ្ធផលវាយតម្លៃបឋម និងរបាយការណ៍លទ្ធផលវាយតម្លៃចុងក្រោយ។

ទម្រង់នៃរបាយការណ៍លទ្ធផលវាយតម្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨ .-**

របាយការណ៍លទ្ធផលវាយតម្លៃបឋម ដែលបានរៀបចំដោយក្រុមការងារវាយតម្លៃ ត្រូវដាក់ឆ្លងកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រធានគ្រប់គ្រងការវាយតម្លៃ និងតួអង្គពាក់ព័ន្ធសំខាន់ៗ មុននឹងដាក់ជូនប្រធានកម្មវិធីពិនិត្យនិងផ្តល់យោបល់។

របាយការណ៍លទ្ធផលវាយតម្លៃចុងក្រោយ ត្រូវដាក់ជូនប្រធានគ្រប់គ្រងការវាយតម្លៃពិនិត្យមុននឹងដាក់ជូនគណៈកម្មការដឹកនាំការវាយតម្លៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៩ .-**

វិធាននិងនីតិវិធីលម្អិតនៃការវាយតម្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## សិទ្ធិអំណាចនិងភារកិច្ចទទួលខុសត្រូវ

**មាត្រា២០ .-**

តួអង្គពាក់ព័ន្ធសំខាន់ៗចំនួន ៥ (ប្រាំ) ក្នុងដំណើរការវាយតម្លៃសមិទ្ធកម្ម រួមមាន៖

១- អ្នកដឹកនាំបញ្ជាការវាយតម្លៃ

២- គណៈកម្មការដឹកនាំការវាយតម្លៃ

៣- ប្រធានគ្រប់គ្រងការវាយតម្លៃ

៤- ប្រធានកម្មវិធី និង

៥- ក្រុមការងារវាយតម្លៃ។

**មាត្រា២១ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកដឹកនាំបញ្ជាការវាយតម្លៃ ដោយមានសិទ្ធិអំណាច ដូចខាងក្រោម៖

- សម្រេចជ្រើសរើសកម្មវិធីរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល សម្រាប់ធ្វើការវាយតម្លៃ
- សម្រេចលើគោលបំណងនៃការវាយតម្លៃ
- ចាត់តាំងគណៈកម្មការដឹកនាំការវាយតម្លៃ និងប្រធានគ្រប់គ្រងការវាយតម្លៃ
- ក្នុងករណីចាំបាច់ អាចប្រើប្រាស់ទីប្រឹក្សាបច្ចេកទេសវាយតម្លៃផ្នែកក្រៅ ព្រមទាំងអាចមានកិច្ចសហការជាមួយដៃគូពាក់ព័ន្ធក្នុងការវាយតម្លៃសមិទ្ធកម្ម
- អនុម័តលើលទ្ធផលនៃការវាយតម្លៃ។

**មាត្រា២២ .-**

គណៈកម្មការដឹកនាំការវាយតម្លៃ ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានសមាសភាពមកពីក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ ដែលមានភារកិច្ច ដូចខាងក្រោម៖

- ផ្តល់ការណែនាំ និងដឹកនាំតួអង្គពាក់ព័ន្ធអនុវត្តការវាយតម្លៃ



ទ

- ដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើវឌ្ឍនភាពការងារ និងរបាយការណ៍លទ្ធផលវាយតម្លៃ
- ពិនិត្យ និងផ្តល់ការយល់ព្រមលើរបាយការណ៍លទ្ធផលវាយតម្លៃ ដើម្បីគោរពរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣ .-**

ប្រធានគ្រប់គ្រងការវាយតម្លៃ ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំក្រុមការងារវាយតម្លៃ
- តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីដំណើរការនៃការវាយតម្លៃ, វឌ្ឍនភាពការងារ, បញ្ហាប្រឈម និងលទ្ធផលនៃការវាយតម្លៃ ជូនគណៈកម្មការដឹកនាំការវាយតម្លៃ
- សម្របសម្រួលការប្រមូលទិន្នន័យ
- ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍លទ្ធផលវាយតម្លៃ
- ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជូនដល់ក្រុមគោលដៅ និង
- ការងារពាក់ព័ន្ធចាំបាច់ផ្សេងទៀត។

**មាត្រា២៤ .-**

ប្រធានកម្មវិធីនៃកម្មវិធីដែលរងការវាយតម្លៃ សំដៅដល់អ្នកទទួលបន្ទុកកម្មវិធីដែលត្រូវបានជ្រើសរើសសម្រាប់ធ្វើការវាយតម្លៃ ដែលមានភារកិច្ច ដូចខាងក្រោម៖

- ផ្តល់កិច្ចសហការ និងសម្របសម្រួលការផ្តល់ព័ត៌មាន និងទិន្នន័យ តាមតម្រូវការចាំបាច់
- ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាវឌ្ឍនភាពការងារ និងរបាយការណ៍លទ្ធផលវាយតម្លៃបឋម
- រៀបចំការឆ្លើយតបនឹងអនុសាសន៍ដែលមានក្នុងលទ្ធផលនៃការវាយតម្លៃ
- រៀបចំផែនការតាមដានការអនុវត្តអនុសាសន៍នៃលទ្ធផលវាយតម្លៃដែលបានឯកភាព និង
- ចូលរួមផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជូនដល់ក្រុមគោលដៅ។

**មាត្រា២៥ .-**

ក្រុមការងារវាយតម្លៃ សំដៅដល់ក្រុមការងារបច្ចេកទេសនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបន្ទុកអនុវត្តការវាយតម្លៃ។

**មាត្រា២៦ .-**

តួនាទី ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥រោច ខែ មិគសិរ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២៥**
**ស្តីពីការតាមដាននិងវាយតម្លៃប្រព័ន្ធថវិកាសមិទ្ធកម្មថ្នាក់ជាតិ**

**សន្ទានុក្រម**

**ផលប៉ះពាល់**(Impact) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលនឹងបង្ហាញអំពីការផ្លាស់ប្តូរ ដែលបានកើតមានឡើង ឬអាចនឹងកើតមានឡើងដោយសារការអនុវត្តកម្មវិធី ដែលការផ្លាស់ប្តូរនេះអាចមានផលវិជ្ជមាន ឬអវិជ្ជមាន ហើយអាចនឹងខុសពីលទ្ធផលដែលបានគ្រោងទុក។

**ចីរភាព** (Sustainability) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលស្វែងយល់អំពីភាពដែលអាចបន្តមាននៃអត្ថប្រយោជន៍របស់កម្មវិធី ដោយពិចារណាលើភាពធន់ ហានិភ័យ ស្ថានភាពហិរញ្ញវត្ថុ សេដ្ឋកិច្ច សង្គម បរិស្ថាន និងសមត្ថភាពរបស់ស្ថាប័ន ដែលចាំបាច់សម្រាប់ទ្រទ្រង់អត្ថប្រយោជន៍ទាំងនោះ នៅពេលខាងមុខ។

**ស័ក្តិសិទ្ធភាព** (Efficiency) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលបង្ហាញថាកម្មវិធីបានផ្តល់ ឬអាចនឹងផ្តល់លទ្ធផលប្រកបដោយភាពសន្សំសំចៃ និងទាន់ពេលកំណត់។

**ប្រសិទ្ធភាព** (Effectiveness) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលអាចបញ្ជាក់ថាគោលបំណងរបស់កម្មវិធីនោះត្រូវបានសម្រេចដោយជោគជ័យ ឬរំពឹងថានឹងសម្រេចបាន។

**ភាពស្របតាមទិសដៅ** (Relevance) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលអាចបញ្ជាក់ថាគោលបំណង និងផែនការរបស់កម្មវិធី ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អ្នកទទួលផល ព្រមទាំងស្របតាមគោលនយោបាយ និងអាទិភាពរបស់រាជរដ្ឋាភិបាល ហើយភាពស្របតាមទិសដៅនៅតែបន្ត ទោះបីជាកាលៈទេសៈមានការប្រែប្រួល។

**ភាពស៊ីសង្វាក់គ្នា** (Coherence) សំដៅដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលអាចបញ្ជាក់ថាកម្មវិធីដែលរងការវាយតម្លៃមានភាពប្រទាក់ក្រឡា ជាមួយនឹងកម្មវិធីផ្សេងទៀតនៅក្នុងប្រទេស វិស័យ ឬស្ថាប័ន។

**វិធីសាស្ត្រវាយតម្លៃ** សំដៅដល់វិធីសាស្ត្រ និងបច្ចេកទេស ដែលប្រើក្នុងការវាស់វែងសមិទ្ធកម្ម ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ឬកម្មវិបាកនៃកម្មវិធី មានដូចជា កិច្ចសម្ភាសន៍ ការអង្កេត ការពិនិត្យលើឯកសារដែលមានស្រាប់ បទសម្ភាសន៍សំខាន់ៗ ការស្ទង់មតិ ការសិក្សាដោយផ្អែកលើការពិសោធន៍ (Randomized Controlled Trails) ឬការវិភាគស្ថិតិ ជាដើម។

**វិធីសាស្ត្របែបគុណភាព** សំដៅដល់វិធីសាស្ត្រនៃការប្រមូលទិន្នន័យដែលមិនមែនជាតួលេខ ប៉ុន្តែជាពាក្យ រូបភាព ឬការអង្កេត។ វិធីសាស្ត្របែបគុណភាពមានដូចជា ការសម្ភាសន៍ក្រុមគោលដៅ ការអង្កេត និងករណីសិក្សាជាដើម។

**វិធីសាស្ត្របែបបរិមាណ** សំដៅដល់វិធីសាស្ត្រនៃការប្រមូលទិន្នន័យជាតួលេខ ដែលអាចវិភាគជាស្ថិតិ។ វិធីសាស្ត្របែបបរិមាណមានដូចជា ការសិក្សាដោយផ្អែកលើការពិសោធន៍ ការស្ទង់មតិ និងការវិភាគស្ថិតិជាដើម។

**របាយការណ៍លទ្ធផលវាយតម្លៃបឋម** សំដៅដល់ឯកសារដែលរៀបចំឡើងដើម្បីបង្ហាញលទ្ធផលបឋមនៃការប្រមូល និងវិភាគទិន្នន័យ របស់ក្រុមការងារវាយតម្លៃ ព្រមជាមួយអនុសាសន៍ សម្រាប់ជាកម្រិត

កិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រធានគ្រប់គ្រងការវាយតម្លៃ និងតួអង្គពាក់ព័ន្ធសំខាន់ៗ ដើម្បីជាមូលដ្ឋានរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃចុងក្រោយ។

**របាយការណ៍លទ្ធផលវាយតម្លៃចុងក្រោយ** សំដៅដល់ឯកសារដែលរៀបចំដោយផ្អែកលើលទ្ធផលនៃកិច្ចពិភាក្សា និងការឆ្លើយតបកម្រិតថ្នាក់គ្រប់គ្រង ( Management Response) ចំពោះលទ្ធផលនៃការវាយតម្លៃ និងអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍លទ្ធផលវាយតម្លៃបឋម។